ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour supreme

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Dec-2015, 10:33
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

---

# សេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាស្តីពីកិច្ចដំណើរការនីតិវិធី ជាមួយនឹងសវនាការលើបណ្តឹងសាទុក្ខ

---

**សហព្រះរាជអាជ្ញា** **សហមេធាវីជនជាប់ចោទ នួន ជា**

ជា លាង
Nicholas KOUMJIAN

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

សុន អរុណ
Victor KOPPE

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F30/16/1

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ (“**អង្គជំនុំជម្រះតុលាការកំពូល**” និង“**អ.វ.ត.ក**”),

**កត់សម្គាល់ឃើញ**ថា “សារណារបស់សហព្រះរាជអាជ្ញាស្តីពីកិច្ចដំណើរការនីតិវិធីជាមួយសវនាការលើបណ្តឹងសាទុក្ខ” ដែលបានដាក់នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (“សំណើ”)[1] ទាក់ទងនឹងទម្រុងជំរុញទៅមុខនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ បន្ទាប់ពីសវនាការបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ដល់ ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ កន្លងមក (“សវនាការបណ្តឹងសាទុក្ខ)[2] ត្រូវបានផ្អាកដោយសារពុំមានការការពារក្តីគ្រប់គ្រាន់សម្រាប់ នួន ជា បណ្តាលមកពីសហមេធាវីការពារក្តីអន្តរជាតិពុំបានចូលរួមសវនាការ និងសហមេធាវីការពារក្តីជាតិបានចាកចេញពីបន្ទប់សវនាការ បើទោះបីជា មានការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលកុំឱ្យចាកចេញពីបន្ទប់សវនាការក៏ដោយ[3],

**រំលឹក**ថា អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចនៅពេលសវនាការលើបណ្តឹងសាទុក្ខនេះ (“សេចក្តីសម្រេចផ្ទាល់មាត់”)[4] និងថា ប្រធានអង្គជំនុំជម្រះក្រោយមកទៀតបានរៀបរាប់លម្អិតនៅក្នុងអនុស្សរណៈ (“អនុស្សរណៈស្តីពីការអនុវត្តន៍តាម”)[5] ថា អង្គភាពគាំពារការការពារក្តី ត្រូវចាត់តាំងមេធាវីបម្រុងសម្រាប់ការពារក្តី នួន ជា ក្នុងករណីដែល នួន ជា ពុំមានជំនួយការផ្នែកច្បាប់សមស្របគ្រប់គ្រាន់នៅពេលណាដែលសវនាការលើបណ្តឹងសាទុក្ខនឹងត្រូវបន្ត ហើយ មេធាវីដែលត្រូវបានចាត់ដោយតុលាការនឹងត្រូវផ្តល់ជំនួយការតាមអាណត្តិនៅក្នុងតុលាការនេះ,

**កត់សម្គាល់ឃើញ**ថា សំណើដែលលើកឡើងថា ក្របខ័ណ្ឌច្បាប់ដែលអាចអនុវត្តបានចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងកាលៈទេសៈបច្ចុប្បន្ន ពុំតម្រូវឱ្យមានវត្តមានរបស់សហមេធាវីការពារក្តី នួន ជា នៅក្នុងបន្ទប់សវនាការក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខឡើយ បានស្នើសុំឱ្យ

---

[1] ឯកសារលេខ F30/16

[2] ដីកាកំណត់កាលវិភាគស្តាពរសម្រាប់សវនាការបណ្តឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវដោះស្រាយ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4។

[3] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1។

[4] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ F1/4.1 ទំព័រ ២៨ ដល់ ៣១។

[5] អនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា “ការអនុវត្តន៍តាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យចាត់តាំងមេធាវីបម្រុងសម្រាប់ការពារក្តី នួន ជា” ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/15។

អង្គជំនុំជម្រះនេះ មិនចាំបាច់បន្តនីតិវិធីចាត់តាំងមេធាវីបម្រុង ហើយជំនួសមកវិញស្នើសុំកំណត់ថាតើ នួន ជា មានបំណងបោះបង់សិទ្ធិទទួលបានជំនួយពីមេធាវីរបស់ខ្លួនពិតប្រាកដមែន ដែរ ឬទេ ប្រសិនបើពិតមែន បន្តសវនាការទៅមុខទៀត ដោយមានជនជាប់ចោទ តែពុំចាំបាច់មានវត្តមានរបស់មេធាវីការពារក្តីណាមួយ នៅក្នុងបន្ទប់សវនាការឡើយ[6],

**ពិចារណាឃើញ**ថា ក្នុងអំឡុងពេលនៃសវនាការលើបណ្តឹងសាទុក្ខ នៅមុនពេលការចេញសេចក្តីសម្រេចផ្ទាល់មាត់ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឱកាសឱ្យភាគីធ្វើសារណាទាក់ទងនឹងបញ្ហាថាតើ ត្រូវបន្តទៅមុខទៀត យ៉ាងដូចម្តេច និងថា សហព្រះរាជអាជ្ញាបានលើកឡើងថា ប្រហាក់ប្រហែលគ្នាទៅនឹងសំណើរបស់ខ្លួននេះដែរ នួន ជា បានបោះបង់សិទ្ធិក្នុងការទទួលបានការការពារក្តីពីមេធាវី និងថា ហេតុនេះ សវនាការ គប្បីបន្តទៅតាមគម្រោង[7],

**ពិចារណាឃើញ**ថា អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញនូវភាពចាំបាច់ ក្នុងការពិចារណាទៅលើអង្គសេចក្តីនៃសំណើនេះ ដោយហេតុថា សំណើសុំដែលមាននៅក្នុងនោះ ត្រូវបានចាត់ជាអាសារបង់ ដោយសេចក្តីសម្រេចផ្ទាល់មាត់ និងអនុស្សរណៈស្តីពីការអនុវត្តន៍តាម ហើយ សហព្រះរាជអាជ្ញា ខកខានក្នុងការបង្ហាញហេតុផលណាមួយដែលគួរឱ្យជឿបាន រួមទាំងការប្រែប្រួលនៃកាលៈទេសៈ ដែលតម្រូវឱ្យមានការពិចារណាឡើងវិញលើបញ្ហានេះឡើយ,

**អាស្រ័យហេតុនេះ÷**

**សម្រេចបដិសេធ**សំណើនេះចោល។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

[6] សំណើ កថាខណ្ឌ ៣៧ ដល់ ៣៨ និង ៤៥។

[7] ប្រតិចារឹក ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ២៦ ដល់ ២៨។